**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
******

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**
* * * * * *

នៅរសៀលថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ២០១៩ **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន** បានអនុញ្ញាតឲ្យ ឯកឧត្តម **Ingo H. Karsten** ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ ចូលជួបសម្តែងការគួរសម និង ជម្រាបលា ក្នុងឱកាសដែលឯកឧត្តមបានបញ្ចប់បេសកកម្មការទូត នៅព្រះរាជាណាចក្រកម្ពុជា។

**ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** បានសម្តែងនូវការពេញចិត្តចំពោះទំនាក់ទំនងរវាងកម្ពុជា និងអាល្លឺម៉ង់ក្នុង រយៈពេលបួនឆ្នាំកន្លងមកនេះ ដែលបានឆ្លុះបញ្ចាំងតាមរយៈ ទំនាក់ទំនងពាណិជ្ជកម្មមានការកើនឡើងរឹងមាំខ្លាំង ជាងគេក្នុងចំណោមប្រទេសនៅអឺរ៉ុប ការផ្លាស់ប្តូរទស្សនកិច្ចកម្រិតខ្ពស់ និងការពិគ្រោះយោបល់ទៀងទាត់ ជា ពិសេសសម្រាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍។ **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** បានថ្លែងអំណរគុណដល់រដ្ឋាភិបាល និង ប្រជាជនអាល្លឺម៉ង់ដែលបានជួយដល់កម្ពុជាលើវិស័យមួយចំនួនដូចជា កសិកម្ម សុខាភិបាល ការដោះមីន វិមជ្ឈការ និងអភិវឌ្ឍន៍ជនបទជាដើម។ ទន្ទឹមនេះ **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** ក៏បានអរគុណ ឯកឧត្តមឯកអគ្គរដ្ឋទូត ចំពោះការខិតខំផ្ទាល់ខ្លួន នៅក្នុងអាណត្តិកន្លងមកនេះ។

ជាការឆ្លើយតបវិញ **ឯកឧត្តមឯកអគ្គរដ្ឋទូត** បានបញ្ជាក់ពីការពេញចិត្តក្នុងការបំពេញការងារនៅកម្ពុជា ពោលគឺចាប់ ពីដើមអាណត្តិមកម្លេះ។ **ឯកឧត្តម** បានធ្វើជាសាក្សីនៃការវិវត្តរីកចម្រើនរបស់កម្ពុជាក្នុងវិស័យសេដ្ឋកិច្ច និងសង្គម ហើយប្រទេសអាល្លឺម៉ង់គឺជាដៃគូសហប្រតិបត្តិការយូរអង្វែងជាមួយកម្ពុជា។ **ឯកឧត្តម** បានកត់សំគាល់ពី ជោគជ័យនៃការពិគ្រោះយោបល់ ហើយអាល្លឺម៉ង់ក៏បានបង្កើនជំនួយអភិវឌ្ឍដល់កម្ពុជា។ ទន្ទឹមនឹងនេះ មានក្រុមហ៊ុន អាល្លឺម៉ង់កាន់តែច្រើនបានចាប់អារម្មណ៍មកវិនិយោគនៅកម្ពុជា ដូចជាក្នុងវិស័យអគ្គិសនី ដែលនេះជាសញ្ញានៃ តម្រូវការសម្រាប់ការអភិវឌ្ឍ។ អាល្លឺម៉ង់ក៏បានផ្តល់អាហារូបករណ៍សម្រាប់បណ្តុះបណ្តាលអ្នកការទូតវ័យក្មេងនៅ កម្ពុជា ដែលរហូតមកដល់ពេលនេះមានចំនួនសរុប ១៣នាក់ហើយ។

**ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** បន្តមានប្រសាសន៍ថា អាល្លឺម៉ង់បានផ្តល់ជំនួយឥតសំណង និងកម្ចី ហិរញ្ញប្បទានសម្បទានចំនួនសែសិបប្រាំបីលានប្រាំមួយសែនអឺរ៉ូ សម្រាប់គម្រោងកាត់បន្ថយភាពក្រីក្រនៅកម្ពុជា ពីឆ្នាំ ២០១៩-២០២០។ ចំណែកឯទំហំពាណិជ្ជកម្មរវាងប្រទេសទាំងពីរវិញ មានចំនួនប្រមាណមួយពាន់លាន ដុល្លា ខណៈដែលភ្ញៀវទេសចរណ៍អាល្លឺម៉ង់មានជាង១០ ម៉ឺននាក់ក្នុងមួយឆ្នាំ។

អំពីបញ្ហា EBA **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** បានជម្រាបជូនឯកឧត្តមឯកអគ្គរដ្ឋទូតថា រាជរដ្ឋាភិបាល កំពុង ខិតខំធ្វើការជាមួយគណៈកម្មការអឺរ៉ុបដើម្បីថែរក្សា EBA សម្រាប់កម្ពុជា ដោយបានរៀបចំទទួលបេសកកម្មគណៈកម្មការ អឺរ៉ុបមកកម្ពុជាកាលពីដើមខែនេះ។ ចំពោះបញ្ហានេះ **ឯកឧត្តមឯកអគ្គរដ្ឋទូត** រីករាយដោយកត់សម្គាល់ឃើញថា

រាជរដ្ឋាភិបាលបានខិតខំធ្វើការងារច្រើន តាមរយៈការតំឡើងប្រាក់បៀវត្សកម្មករ និងការសម្រាកមាតុភាពជាដើម ដែលផ្នែកមួយនៃការគាំពារសង្គម។

**ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** មានប្រសាសន៍ថា រាជរដ្ឋាភិបាលប្តេជ្ញាពង្រឹងលទ្ធិប្រជាធិបតេយ្យ សេរីភាពសាព័ត៌មាន និងសង្គមស៊ីវិល សហជីព ដែលរហូតមកដល់ពេលនេះមានការលើកលែងទោសដល់មេសហជីព និងបង្កើតវេទិកាពិគ្រោះយោបល់ជាមួយសង្គមស៊ីវិល។

**ឯកឧត្តមឯកអគ្គរដ្ឋទូត** មានការកោតស្ញប់ស្ញែងចំពោះប្រសាសន៍របស់សម្តេចតេជោនាយករដ្ឋមន្ត្រីថា សម្តេចតែងតែពិភាក្សាជាមួយបក្សប្រឆាំង។

នៅក្នុងកិច្ចសហប្រតិបត្តិការតំបន់វិញ **ឯកឧត្តមឯកអគ្គរដ្ឋទូត** បានមានប្រសាសន៍ថា សហគមន៍អឺរ៉ុបមានការចាប់អារម្មណ៍ខ្លាំងលើអាស៊ាន និងចង់ពង្រីកទំនាក់ទំនងជាមួយអាស៊ានលើសពីវិស័យសេដ្ឋកិច្ចទៅដល់វិស័យនយោបាយ និងសន្តិសុខ។

**ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** និង **ឯកឧត្តមឯកអគ្គរដ្ឋទូត** បានឯកភាពគ្នាថា នឹងបន្តពិភាក្សាសម្រេចឲ្យបាននូវអនុស្សរណៈស្តីពីការពិគ្រោះយោបល់រវាងក្រសួងការបរទេសទាំងពីរ ហើយនឹងបន្តគាំទ្រគ្នាទៅវិញទៅមកនៅក្នុងយន្តការពហុភាគីនានា ដូចជា អ.ស.ប. និងអង្គការយូណេស្កូជាដើម។

ជំនួបនេះ បានបញ្ចប់ក្នុងបរិយាកាសរីករាយ និងស្និទ្ធស្នាល៕

ថ្ងៃសៅ ១២ រោច ខែជេស្ឋ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣
ភ្នំពេញ ថ្ងៃទី ២៩ ខែមិថុនា ឆ្នាំ ២០១៩